# តារាងស្តីពីព័ត៌មានរបស់គម្រោង

លេខPIP : 1189

(សម្រាប់បំពេញដោយក្រសួងផែនការ)

## ព័ត៌មានមូលដ្ឋានអំពីគម្រោង

*(ត្រូវបំពេញគ្រប់ចំណុចទាំងអស់)*

## ផ្នែក ក

១. ឈ្មោះគម្រោង : គម្រោងសាងសង់អគារពន្ធនាគារ

២. កាលបរិច្ឆេទគម្រោង

| | |
|---|---|
| កាលបរិច្ឆេទចាប់ផ្តើមគម្រោង | 01/01/25 |
| កាលបរិច្ឆេទបញ្ចប់គម្រោង | 31/12/27 |

៣. ចំណាយគម្រោងសរុប $24,673,054

៤. ស្ថាប័នទទួលខុសត្រូវ ក្រសួងមហាផ្ទៃ

| | |
|---|---|
| RESPONSIBLE UNIT | General Department of Prison |
| អង្គភាពទទួលខុសត្រូវ | អគ្គនាយកដ្ឋានពន្ធនាគារ |

៥. ស្ថានភាពគម្រោង គម្រោងសម្រាប់អនុវត្តផ.យ.អ.ជ.

ព័ត៌មានលម្អិតអំពីគម្រោង

៦. ប្រភេទគម្រោង ៖ គម្រោងវិនិយោគជាទុន

៧. ប្រភពហិរញ្ញប្បទាន៖ ថវិកាជាតិ

៨. មុំនៃគោលនយោបាយក្នុងយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ ដែលគម្រោងស្ថិតនៅ
បរិស្ថានគ្រប់ដណ្តប់

៩. ការចូលរួមចំណែករបស់គម្រោងក្នុងការសម្រេចបានគោលនយោបាយអាទិភាពខាងលើ

- ពន្ធនាគារមានហេដ្ឋារចនាសម្ព័ន្ធ គោរពតាមបទដ្ឋានអប្បបរមា សម្រាប់ការសាងសង់ពន្ធនាគារ ដែលបានកំណត់ដោយប្រកាសរបស់ក្រសួងមហាផ្ទៃ។
- អគារ និងបន្ទប់ឃុំឃាំង ត្រូវមានពន្លឺគ្រប់គ្រាន់ មានខ្យល់ធម្មជាតិ មានបន្ទប់អនាម័យមានប្រព័ន្ធផ្គត់ផ្គង់ទឹក និងអគ្គិសនីសម្រាប់ប្រើប្រាស់នៅក្នុងមណ្ឌលអប់រំកែប្រែ និងពន្ធនាគាររាជធានី ខេត្ត។
- ពន្ធនាគារត្រូវមានប៉ុស្តិ៍សុខភាព មានបន្ទប់សម្រាប់ព្យាបាលជនជាប់ឃុំ មានមន្ត្រីសុខាភិបាលបំរើជាប្រចាំ។
- ពន្ធនាគារត្រូវមានកន្លែងសម្រាប់ គោរពជំនឿសាសនា មានបណ្ណាល័យ និងអគារអប់រំបណ្តុះបណ្តាលវិជ្ជាជីវៈ ដល់ជនជាប់ឃុំទាំងពីរភេទដូចជា៖ ជាងកាត់ដេរសំលៀកបំពាក់បុរស ឬស្ត្រី ជាងកាត់សក់ សំអាងកាយ ដេរប៉ាក់ អ៊ុតសក់ តន្ត្រីសម័យ អ្នកចម្រៀងភ្លេងបុរាណ គំនូរ ជាងចំលាក់ឈើ ថ្ម ជាងសំណង់ តបណ្តាញអគ្គិសនី ជាងជួសជុលកុំព្យូទ័រ រថយន្ត ម៉ូតូ ជាងផ្សារដែក ជាងកែច្នៃចង្ក្រាន ឧស្មន័ សម្រាប់ធ្វើការដាំស្ល ។ល។
- ពន្ធនាគារត្រូវបានរៀបចំអោយមានកន្លែងហាត់ប្រាណដល់ជនជាប់ឃុំ។
- ពន្ធនាគារត្រូវមាន ផ្ទះមុខងារសម្រាប់មន្ត្រីពន្ធនាគារក្នុងអំឡុងពេលបំពេញមុខងាររបស់ខ្លួន។
- ពន្ធនាគារសំដៅកន្លែងប្រើសម្រាប់ធ្វើការឃុំឃាំងជនជាប់ឃុំតាមលិខិតឃុំខ្លួនចេញដោយអាជ្ញាធរតុលាការ រួមមានមណ្ឌលឃុំខ្លួន មណ្ឌលកែប្រែ ដែលបែងចែកទៅតាមប្រភេទដូចជា ជនត្រូវចោទ ជនជាប់ចោទ ពិរុទ្ធជន ឬទណ្ឌិតដែលត្រូវបានបញ្ជូនមកឃុំខ្លួននៅក្នុងពន្ធនាគារ ជនជាប់ឃុំត្រូវគោរព និងអនុវត្តតាមបទបញ្ជាផ្ទៃក្នុងពន្ធនាគារ និងការណែនាំរបស់មន្ត្រីពន្ធនាគារ។

## ១០. ការគាំទ្រដល់គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា

តើគម្រោងនេះគាំទ្រដល់ការអនុវត្តគោលនយោបាយអភិវឌ្ឍន៏វិស័យឧស្សាហកម្មកម្ពុជាដែរឬទេ? មិនគាំទ្រ

## ១១. វិស័យ (សូមប្រើវិស័យ អនុវិស័យ ដែលមានចែងក្នុងផ.យ.អ.ជ.)

| | |
|---|---|
| អភិបាលកិច្ច និងរដ្ឋបាល | Governance and Administration |
| | Governance and Administration |
| | Governance and Administration |

## ១២. ទីតាំងអនុវត្តគម្រោង (ពិពណ៌នាពីទីតាំងដែលត្រូវអនុវត្តគម្រោង)

បន្ទាយមានជ័យ, រាជធានីភ្នំពេញ, កណ្តាល, កែប, រតនគីរី, ត្បូងឃ្មុំ , បាត់ដំបង, ពោធិ៍សាត់,

## ១៣. គោលបំណងរបស់គម្រោង (ពិពណ៌នាគោលបំណងចម្បងៗរបស់គម្រោង)

- សាងសង់ឡើងវិញជំនួសនូវ អគារដែលមានសភាព ចាស់ទ្រុឌទ្រោម បាក់ប្រេះ ស្រុត សំណង់ហួសអាយុកាលដែលធ្លាប់ទទួលរងការខូចខាតពីសង្គ្រាមយ៉ាងដំណំកន្លងមក ។
- ដើម្បីឆ្លើយតបទៅហ្នឹងកំណើនកើនឡើងរបស់ជនជាប់ឃុំ លើសពីការព្យាករណ៍ ។
- ដើម្បីទប់ស្កាត់ការខូចខាតដែលបង្កឡើងដោយគ្រោះធម្មជាតិ ភ្លៀង ខ្យល់ព្យុះ ខ្យល់កន្ត្រាក់ រន្ទះ ទឹកជំនន់ ការកើនឡើងកំដៅ ។
- ផ្តល់បរិយាកាសប្រកបដោយ ផាសុខភាពស្នាក់នៅរបស់ជនជាប់ឃុំ ដើម្បីកាត់បន្ថយអារម្មណ៍តានតឹង ពីការព្យាយាមចង់រត់គេចខ្លួនចេញពីពន្ធនាគារ តាមគ្រប់រូបភាព ។ល។
- មានទីតាំងសមស្របសម្រាប់ធ្វើការអប់រំកែប្រែ បំណិនជីវិត និងស្មារតីសីលធម៌ បណ្តុះបណ្តាលវិជ្ជាជីវៈដល់ទណ្ឌិត។

១៤. ការពិពណ៌នាអំពីគម្រោង (ពិពណ៌នាអំពីសមាសភាគទាំងអស់របស់គម្រោង)

ឆ្នាំ២០២៥ : សាងសង់ពន្ធនាគាររាជធានីភ្នំពេញ(ដំណាក់កាលទី៥) និងសាងសង់ពន្ធនាគារខេត្តកែប
សាងសង់ពន្ធនាគារខេត្តបន្ទាយមានជ័យ
និងមណ្ឌលអប់រំកែប្រែទណ្ឌិតបទល្មើសគ្រឿងញៀន(ខេត្តពោធិ៍សាត់)
ឆ្នាំ២០២៦ : អគារពង្រីកបន្ថែមនៃមណ្ឌលអប់រំកែប្រែទី១(ភ្នំពេញ) សាងសង់ពន្ធនាគារខេត្តកណ្តាល
និងសាងសង់អគារពង្រីកបន្ថែមពន្ធនាគារ
ខេត្តបាត់ដំបង
ឆ្នាំ២០២៧ : អគារ៦ខ្នងនៃមណ្ឌលអប់រំកែប្រែទី៣ (ត្បូងឃ្មុំ) សាងសង់ពន្ធនាគារខេត្តរតនគិរី។

១៥. យុត្តិកម្មលើគម្រោង (បង្ហាញពីហេតុផលថាហេតុអ្វីបានជាគម្រោងនេះត្រូវបានជ្រើសរើស)

ដើម្បីកាត់បន្ថយការចង្អៀតណែន លើសចំណុះ និងផ្តល់សារៈសំខាន់ បរិយាកាសដ៏សមរម្យរហូតដល់ថ្ងៃបញ្ចប់ការអនុវត្តទោស (ឧទាហរណ៏៖ ជនជាប់ឃុំ នឹងរៀនទម្លាប់រស់នៅជាមួយគ្នា ដែលអាចកាត់បន្ថយ ស្មារតីគិតខ្លី ប៉ុនប៉ងធ្វើអត្តឃាតជាដើម។

១៦. ផលប្រយោជន៍របស់គម្រោង (រៀបរាប់ពីអ្នកដែលនឹងទទួលប្រយោជន៍ផ្ទាល់និងមិនផ្ទាល់ពីការអនុវត្តគម្រោង)

អ្នកទទួលប្រយោជន៍ផ្ទាល់៖

--មន្ត្រីពន្ធនាគារទាំងអស់ងាយស្រួលក្នុងការស្នាក់នៅ យាមកាម ក្នុងការគ្រប់គ្រង ឃ្លាំមើល ស៊ើបអង្កេត ឆែកឆេរ ក្តោបរាល់សភាពការណ៍ អសន្តិសុខទាំងឡាយភ្លាមទាន់ពេលវេលា ដែលគ្រោង នឹងបង្ករឡើង ដោយជនជាប់ឃុំ (ឧទាហរណ៏៖ ការចង់បះបោល រំដោះអ្នកទោស ការបង្កជម្លោះរវាងអ្នកទោស និងអ្នកទោស ។ល។
--រាល់ជនជាប់ឃុំជាស្ត្រីមានភាពកក់ក្តៅតាមរយៈ ការស្នាក់នៅក្នុងអគារជាស្ត្រីដូចគ្នា ដោយយល់សុខទុក្ខក្នុងនាមជា ស្ត្រីភេទដូចគ្នា។

អ្នកមិនទទួលប្រយោជន៍ផ្ទាល់

--សាច់ញ្ញាតិរបស់ជនជាប់ឃុំ មានអគារសម្រាប់ជួបសួរសុខទុក្ខផ្ទាល់ នៅពេលពួកគេនឹករលឹកក្រុមគ្រួសាររបស់ពួកគេ ។
--មេធាវីមានបន្ទប់ស្ងប់ស្ងាត់ស៊ើបសួរគ្រប់គ្រងរឿងរ៉ាវផ្សេងៗដែលពាក់ព័ន្ធនៅក្នុងបណ្តឹង ជាមួយជនជាប់ឃុំក្នុងលក្ខ័ខណ្ឌសម្ងាត់ ។
--ជាអគារដែលមានសុវត្ថិភាពដ៏រឹងមាំ សាងសង់ ស្របតាមស្តង់ដាបច្ចេកទេស ក៏ដូចជាទីទំនុកចិត្តដ៏កក់ក្តៅរបស់បងប្អូនប្រជាពលរដ្ឋដែលរស់នៅក្បែរបរិវេណពន្ធនាគារ ដែលនឹងមិនភ័យព្រួយពីការលួចរត់គេចខ្លួនចេញ ពីពន្ធនាគារជាញឹកញាប់សំដៅចូលទៅក្នុងផ្ទះ បង្ករការភិតភ័យឡើយ។

១៧. ការសិក្សាសមិទ្ធិលទ្ធភាព

តើគម្រោងនេះតម្រូវឲ្យមានការសិក្សាសមិទ្ធិលទ្ធភាពដែរ ឬទេ? គ្មាន

ប្រសិនបើត្រូវការ តើការសិក្សាសមិទ្ធិលទ្ធភាព បានរៀបចំហើយឬនៅ? មិនទានចាប់ផ្តើម

១៨. ផលប៉ះពាល់ផ្នែកបរិស្ថាននិងសង្គម (ពិពណ៌សង្ខេបពីផលប៉ះពាល់របស់គម្រោងលើប្រជាជននិងបរិស្ថានជុំវិញ ប្រសិនបើមាន។ តើគម្រោងនេះនឹងជួយដល់ការកាត់បន្ថយភាពក្រីក្រដែរឬទេ?)

- គម្រោងនេះមិនមានផលប៉ះពាល់ដល់ប្រជាជន និងបរិស្ថានជុំវិញពន្ធនាគារទេ ផ្ទុយទៅវិញ ថែមទាំងអាចកាត់បន្ថយភាពក្រីក្រដល់ក្រុម គ្រួសារជនជាប់ឃុំទៀតផង។

១៩. ការប្រែប្រួល អាកាសធាតុ

ក. តើសកម្មភាព ឬធាតុចេញរបស់គម្រោងទាក់ ទងនឹងការប្រែប្រួលអាកាសធាតុ ឬទេ? គ្មាន

ខ. តើគម្រោងមានភាពទាក់ទងនឹងការប្រែប្រួលអាកាសធាតុកម្រិតណា?

សូមជ្រើសរើសវិស័យដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុរបស់គម្រោងនិងបំពេញការចូលរួមចំណែកនៃចំណាយដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុរបស់គម្រោងធៀបនឹងតម្លៃគម្រោងសរុប។

| វិស័យដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុ | ភាគរយ | ភាពទាក់ទងនឹងការប្រែប្រួលអាកាសធាតុ |
|---|---|---|

**២០. ការកាត់បន្ថយ ហានិភ័យ និង គ្រោះមហន្តរាយ**

តើសកម្មភាព ឬធាតុចេញរបស់គម្រោងទាក់ទងនឹងការកាត់បន្ថយហានិភ័យ និងគ្រោះមហន្តរាយដែរឬទេ? **គ្មាន**

**២១. ការវិភាគយេនឌ័រ** (តើគម្រោងនេះមានផលប៉ះពាល់ដល់តួនាទីរបស់បុរសនិងស្ត្រីក្នុងទីតាំងរបស់គម្រោងនេះដូចម្តេច? តើស្ត្រីនឹងត្រូវចូលរួមយ៉ាងសកម្មក្នុងការអនុវត្តគម្រោងនេះដែរឬទេ?)

**គម្រោងនេះគឺបានធ្វើការបែងចែកអគារឃុំឃាំង រវាងបុរស និងស្ត្រី ។ មន្ត្រីពន្ធនាគារជាស្ត្រីត្រួតពិនិត្យ និងការពាររក្សាសន្តិសុខដល់ជនជាប់ឃុំជាស្ត្រី។**

**២២. សមត្ថភាពអនុវត្តគម្រោង** (តើក្រសួងមានជំនាញនិងបទពិសោធន៍គ្រប់គ្រាន់សម្រាប់អនុវត្តគម្រោងដែរឬទេ?)

**គម្រោងសាងសង់ពន្ធនាគារត្រូវបានសិក្សាលម្អិតដោយមន្ត្រីជំនាញនៃការិយាល័យស្ថាបនា និងថែទាំសំណង់**

**២៣. ស្ថានភាពនៃការអនុវត្តគម្រោង** (ពិពណ៌នាសង្ខេបអំពីវឌ្ឍនភាពរបស់គម្រោងនិងបង្ហាញអំពីភាពប្រឈមនានា ដែល បណ្តាលឲ្យមាន ការព្យាពេលក្នុងការអនុវត្តគម្រោង។)

**ក្នុងតំបន់ខ្លះក៏ពើបប្រទះនឹងលក្ខខ័ណ្ឌធម្មជាតិដែលកើតឡើងដោយយថាហេតុ។**

**២៤. អាទិភាពរបស់គម្រោង** (បញ្ជាក់ពីការកំណត់អាទិភាពរបស់គម្រោងរបស់ក្រសួង ស្ថាប័ន)

2

**២៥. ការចូលរួមរបស់ដៃគូអភិវឌ្ឍ** (ផ្តល់ព័ត៌មានអំពីដៃគូអភិវឌ្ឍសក្តានុពល ដែលពាក់ព័ន្ធនឹងគម្រោងនេះ)

**មិនមាន**

## ផ្នែក ខ ចំណាយរបស់គម្រោងនិងប្រភពហិរញ្ញប្បទាន

*(គិតជាពាន់ដុល្លារអាមេរិក)*

| ចំណាយវិនិយោគ | 2023 | | 2024 | 2025 | 2026 | 2027 | សរុប | ថវិកា |
|---|---|---|---|---|---|---|---|---|
| | ថវិកា | ដាក់ស្តែង | ថវិកា | ប៉ាន់ស្មាន | ប៉ាន់ស្មាន | ប៉ាន់ស្មាន | 2025-2027 | ចរន្ត |
| **ចំណាយប្រតិបត្តិ** | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | |
| បៀវត្សរ៍ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| សម្ភារៈនិងរដ្ឋបាល | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| ផ្សេងៗ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | |
| **ចំណាយមូលធន** | 0.0 | 0.0 | 0.0 | 11,496.0 | 8,889.2 | 4,287.9 | 24,673.1 | 0.0 |
| | | | | | | | | |
| ការសាងសង់ | 0.0 | 0.0 | 0.0 | 11,496.0 | 8,889.2 | 4,287.9 | 24,673.1 | 0.0 |
| សេវាទីប្រឹក្សា | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| ទព្វសម្ភារៈ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| ការបណ្តុះបណ្តាល | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| ផ្សេងៗ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | |
| **ចំណាយសរុប** | 0.0 | 0.0 | 0.0 | 11,496.0 | 8,889.2 | 4,287.9 | 24,673.1 | 0.0 |
| | | | | | | | | |

| ប្រភពហិរញ្ញប្បទាន | 2023 | | 2024 | 2025 | 2026 | 2027 | សរុប | |
|---|---|---|---|---|---|---|---|---|
| | ថវិកា | ជាក់ស្តែង | ថវិកា | ប៉ាន់ស្មាន | ប៉ាន់ស្មាន | ប៉ាន់ស្មាន | 2025-2027 | |
| | | | | | | | | |
| **ចំណូលពីគម្រោង** | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| **ថវិកាជាតិ** | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| សាច់ប្រាក់សុទ្ធ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| ធនធានផ្សេងៗ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| **ហិរញ្ញប្បទាន របស់ ដៃគូអភិវឌ្ឍ** | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| **សរុបហិរញ្ញប្បទាន ដែលបានសន្យាផ្តល់** | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| **តម្រូវហិរញ្ញប្បទាន បំពេញបន្ថែម** | 0.0 | 0.0 | 0.0 | 11,496.0 | 8,889.2 | 4,287.9 | 24,673.1 | |

**បានឃើញ និង ឯកភាព**

**រដ្ឋមន្ត្រី**

កាលបរិច្ឆេទ: